DSHS 22-722X CA (Rev. 10/08)

Washington State
Department of Social
& Health Services



# នរណា
# អ្វី
# ទីណា
# របៀបណា ?



Aging & Disability Services

Washington State
Department of Social
& Health Services

www.dshs.wa.gov/ddd/index.shtml

## នរណា

### តើ *DDD* សំរាប់នរណា?

បុគ្គលមួយរូបដែលមានពិការភាពផ្នែកការលូតលាស់អាចមានលក្ខណ:សម្បត្តិសំរាប់សេវាកម្ម DDD កាលណា ៖

- ការចាប់ផ្តើមនៃពិការភាពបានកើតឡើងមុនអាយុ 18 ។
- ពិការភាពត្រូវបានរំពឹងថា ត្រូវបន្តទៅជានិរន្តរ៍; ហើយ
- ពិការភាពបណ្តាលឲ្យមានការកម្រិតជាទម្ងន់ដល់ចលនាផ្លាស់ប្តូរបស់ជននោះ ។

ពិការភាពផ្នែកការលូតលាស់គឺជា ៖

- ដំណើរយឺតយ៉ាវនៃការលូតលាស់ផ្នែកសតិ
- ជម្ងឺខួរក្បាលដែលបណ្តាលឲ្យស្វាប់អវ:យវ:
- ជម្ងឺស្កន់
- ជម្ងឺនៃអាការភ័ន្តវិញ្ញាណ
- ជម្ងឺប្រសាទសាស្ត្រផ្សេងៗដែលប្រហាក់ប្រហែលគ្នានឹងដំណើរយឺតយ៉ាវនៃការលូតលាស់ផ្នែកសតិដែរ (រួមមានដូចជា ដំណើរយឺតយ៉ាវខាងការចម្រើនលូតលាស់ជាដើម)

DDD កំណត់លក្ខណសម្បត្តិដោយផ្អែកលើលក្ខណវិនិច្ឆ័យក្នុងច្បាប់ Chapter 388-823 WAC ។ បើគ្រាន់តែមានលក្ខណសម្បត្តិទទួលសេវាកម្មមិនធានាថា អាចទទួលសេវាបង់ប្រាក់បាននោះទេ ។

លទ្ធភាពរបស់អ្នកក្នុងការទទួលសេវាបង់ប្រាក់អាស្រ័យលើ ៖

- លក្ខណសម្បត្តិជួបតាមសេចក្តីតម្រូវរបស់អ្នកសំរាប់សេវាកម្មជាក់លាក់ណាមួយ;
- សេចក្តីត្រូវការដែលទទួលបានចំណាត់ថ្នាក់សំរាប់សេវាកម្ម; និង
- មូលនិធិដែលមានសំរាប់សេវាកម្ម ។

### តើ DDD ជាអ្វី?

នាយកដ្ឋាននៃជនមានពីការភាពផ្នែកការលូតលាស់ (DDD) គឺជាសាខានៃក្រសួងសង្គមកិច្ចនិងសុខាភិបាល (DSHS), អភិបាលកិច្ចគ្រប់គ្រងសេវាជរាភាពនិងពិការភាព (ADSA) ។ DDD ជួយបុគ្គលដែលមានពិការភាពផ្នែកការលូតលាស់និងក្រុមគ្រួសាររបស់ពួកគេ ឲ្យទទួលបាន នូវសេវាកម្មនិងកិច្ចឧបត្ថម្ភនានា ដោយផ្អែកលក្ខណ:ជ្រើសរើស, សមត្ថភាព, និងសេចក្តីត្រូវការរបស់បុគ្គលម្នាក់ៗ ។

## អ្វី

DDD ប្រើមូលនិធិរបស់រដ្ឋនិងសហព័ន្ធដើម្បីផ្តល់ ឬទិញកិច្ចឧបត្ថម្ភនិងសេវាកម្មសំរាប់ជនដែលមានលក្ខណសម្បត្តិទទួលសេវានិងក្រុមគ្រួសារ របស់ពួកគេ ។ ធនធានត្រូវបានកំណត់ ហើយសេវាកម្មដែលត្រូវការ ប្រហែលជាមិនអាចមានជានិច្ចនិរន្តរ៍នោះទេ ។

### តើកិច្ចឧបត្ថម្ភនិងសេវាកម្មអ្វីខ្លះ?

#### ការចាត់ចែងសំណុំរឿង **(Case Management)**

ប្រសិនបើអ្នកត្រូវបានកំណត់ថា មានលក្ខណសម្បត្តិ DDD, អ្នកនឹងត្រូវគេចាត់ឲ្យមាននាយកគ្រប់គ្រងធនធានសំណុំរឿងម្នាក់ ដើម្បីជួយអ្នក និងគ្រួសាររបស់អ្នក ៖

- សំគាល់ផលប្រយោជន៍និងសេចក្តីត្រូវការខាងកិច្ចឧបត្ថម្ភ;
- សម្របសម្រួលគម្រោងផែនការណ៍និងកិច្ចអភិវឌ្ឍន៍នៃធនធាន; ហើយនិង
- ពិនិត្យមើលការចែកចាយសេវាកម្ម ។

#### សេវាថែទាំឯកជនផ្អែកកម្មវិធីមេឌីខេដ/ជំនួយអនុគ្រោះ **(MPC/WPC)**

សេវា MPC/WPC រួមមាននូវការគ្រប់គ្រងឬជំនួយផ្ទាល់ដៃជាមួយនឹងការងារថែទាំផ្ទាល់ខ្លួនសំរាប់បុគ្គលទាំងឡាយ ដែលជួបតាមលក្ខណវិនិច្ឆ័យ ផ្អែកវិជ្ជមានភាពនិងហិរញ្ញវត្ថុ ។ ជំនួយនេះត្រូវបានផ្តល់ជូននៅតាមគេហដ្ឋានរបស់សាមីជនផ្ទាល់, តាមមន្ទីរថែទាំទីតិជន (AFH), ឬតាមមណ្ឌលថែទាំទីតិជនឯកជន (ARC) ។

សេវា MPC គឺជាសេវាកម្មមួយដែលបានផ្តល់ជូន ក្រោមផែនការណ៍របស់រដ្ឋផ្អែកកម្មវិធីមេឌីខេដ ហើយអាចមានជូនដល់ជនណា ដែលជួបតាមលក្ខណវិនច្ឆ័យផ្អែកវិជ្ជមានភាពនិងហិរញ្ញ
វត្ថុរបស់កម្មវិធីជំនួយផ្អែកសេចក្តីត្រូវការពិសេស (CNP) ។

#### ការបម្រើការងារ **(Employment)**

សេវាឧបត្ថម្ភនិងការហ្វឹកហ្វឺនដែលកំពុងបន្តប្រព្រឹត្តទៅ សំរាប់ជនដែលមានលក្ខណសម្បត្តិ ដើម្បីទទួលនិងរក្សាទុកការងារដែលមានបៀវត្សរ៍ ក្នុងសណ្ឋាននៃការចាត់ចែងនិងកន្លែងធ្វើការងារច្រើនបែបច្រើនយ៉ាង ។ អាចរួមមាននូវជម្រើសជាបគ្គលឬជាក្រុមនៅតាមសហគមន៍ ឬក្នុងសេវាកម្មប្រុងប្រៀបសំរាប់ប្រកបវិជ្ជាជីវះ ដើម្បីជួយបណ្តាជនឲ្យអាចបោះជំហានទៅរកការបម្រើការងារបាន ។

#### សិទ្ធិទទួលសេវាសហគមន៍ **(Community Access)**

សកម្មភាព, ជំនួយពិសេស, ការគាំពារ, និងការអប់រំដើម្បីជួយអ្នកមានលក្ខណសម្បត្តិ ចាប់ពីអាយុ 62 ឡើងទៅ ឲ្យចូលរួមយ៉ាងសកម្មនៅក្នុងសហគមន៍របស់ពួកគេ ។

# អ្វី

### កម្មវិធីអន្តរាគមន៍បឋមវ័យសំរាប់ទារកនិងកុមារក្មេងខ្ចី (Infant Toddler Early Intervention Program)

សេវាអន្តរាគមន៍បឋមវ័យ, ដោយរួមមាននូវការសម្របសម្រួលធនធានគ្រួសារ, សំរាប់ក្មេងដែលមានលក្ខណសម្បត្តិពីកំណើតរហូតដល់អាយុ 3 ឆ្នាំ និងគ្រួសាររបស់ពួកគេ ។

### កិច្ចឧបត្ថម្ភគ្រួសារ (Family Support)

សេវាបុគ្គលនិងសហគមន៍ដើម្បីជួយក្រុមគ្រួសារក្នុងការថែទាំសំរាប់សមាជិកគ្រួសាររបស់ពួកគេនៅក្នុងគេហដ្ឋានពួកគេ ។ សេវាកម្មរួមមាននូវ ការថែទាំជំនួសបណ្តោះអាសន្នម្តងៗ និងវិធីព្យាបាលនានា ។

### ការចិញ្ចឹមក្មេងជាបណ្តោះអាសន្ន (Foster Care)

ការដាក់ក្មេងឲ្យចិញ្ចឹមដោយស្ម័គ្រចិត្តនៅក្នុងមន្ទីរចិញ្ចឹមក្មេងបណ្តោះអាសន្ន, ក្រោមកាលៈទេសៈខ្លះ, សំរាប់ក្មេងដែលមានអាយុក្រោម 18 ឆ្នាំ ។

### កិច្ចឧបត្ថម្ភសហគមន៍ (Community Supports)

ការថែទាំព្យាបាល, សេវាឯកទេសជំនាញនិងវិធីព្យាបាលនានា, ការដឹកជញ្ជូន, និងសេវាវេជ្ជសាស្ត្រកម្រិតខ្ពស់ដែលមិនរ៉ាប់រងដោយកម្មវិធី មេឌីខេដ ។

### សេវាបំរើអសមត្ថភាពជន (Residential Services)

សេវាកម្មនិងការឧបត្ថម្ភត្រូវបានផ្តល់ទៅតាមលក្ខណៈនៃការចាត់ចែងផ្សេងៗ ដើម្បីជួយឲ្យសាមីជនអាចរស់នៅដោយមិនពឹងពាក់អ្នកដទៃ នៅក្នុងសហគមន៍បាន ។ សេវាទាំងនេះអាចត្រូវផ្តល់ជូននៅក្នុងគេហដ្ឋានរបស់សាមីជនផ្ទាល់ តាមរយៈអ្នកផ្តល់សេវាបំរើដែលមានអាជ្ញាប័ណ្ណ ឬតាមរយៈបុគ្គល, ឬក្នុងមន្ទីរដែលមានអាជ្ញាប័ណ្ណនានា ។ កម្រិតនៃការផ្តល់សេវាឧបត្ថម្ភគឺផ្អែកទៅលើសេចក្តីត្រូវការនិមួយៗ, ហើយខុសៗគ្នាពីបីបួនម៉ោងក្នុងមួយខែរហូតដល់ 24 ម៉ោងក្នុងមួយថ្ងៃ ។

### មជ្ឈមណ្ឌលទីតិសម្បទារកម្មគេហជន (RHC)

មន្ទីរប្រតិបត្តិកម្មគេហជន ចំនួន 5 រដ្ឋ បានផ្តល់សេវាកម្មកម្រិតខ្ពស់សំរាប់ជនទាំងឡាយណា ដែលត្រូវការការថែទាំព្យាបាលកម្រិតខ្ពស់ ឬផ្អែក អភិវឌ្ឍន៍ជំនាញ ។ សេវាថែទាំជំនួសបណ្តោះអាសន្នម្តងៗ និងសេវាឯកទេសកម្មដទៃៗទៀតអាចមានជូនដល់ជនទាំងឡាយ ដែលកំពុងរស់នៅក្នុងសហគមន៍ ។

# របៀបណា

## តើខ្ញុំទទួលកិច្ចឧបត្ថម្ភនិងសេវាកម្មដោយរបៀបណា?

1. ចូរទូរស័ព្ទទៅការិយាល័យ DDD ប្រចាំតំបន់របស់អ្នក ឬអានមើលសៀវភៅទូរស័ព្ទ ក្រោមមាតិការដ្ឋវ៉ាស៊ិនតោន, ក្រសួងសង្គមកិច្ច និងសុខាភិបាល, នាយកដ្ឋាននៃជនមានពិការភាពផ្នែកការលូតលាស់ ។
2. សួររកលិខិតដាក់ពាក្យសុំសំរាប់ការកំណត់លក្ខណសម្បត្តិ ។ អ្នកត្រូវតែផ្ញើលិខិតដាក់ពាក្យសុំត្រឡប់ទៅវិញ ហើយបន្តធ្វើការកំណត់លក្ខណសម្បត្តិ ដើម្បីឲ្យដឹងថា តើអ្នកឬសមាជិកគ្រួសាររបស់អ្នកមានលក្ខណសម្បត្តិឬទេ ។
3. បើអ្នកឬសមាជិកគ្រួសាររបស់អ្នកមានអាសន្ន ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ជាបន្ទាន់, ឬអ្នកមិនអាចមកជួបសម្ភាសន៍បានទេ, ចូរប្រាប់ដល់អ្នកធ្វើការ នៅពេលដែលអ្នកទូរស័ព្ទទៅជួបគេ ។ DDD មិនអាចផ្តល់ជូនសេវាបង់ប្រាក់បានទេ ទាល់តែអ្នកត្រូវបានកំណត់ថាមានលក្ខណសម្បត្តិសំរាប់ DDD ជាមុនសិន, ក៏ប៉ុន្តែអាចជួយផ្តល់ជាពត៌មាននិងការណែនាំបញ្ជូនបាន ។
4. បើអ្នកមានសំណួរអ្វីមួយស្តីអំពីការអភិវឌ្ឍន៍របស់ទារកអ្នក, សូមទូរស័ព្ទហៅទៅបណ្តាញទូរស័ព្ទសុខភាពគ្រួសារ (Family Health Hotline) ឬកម្មវិធីអន្តរាគមន៍បឋមវ័យនៃទារក-ក្មេងចេះដើរតេសតាស់ (Infant Toddler Early Intervention Program)។ ចូរសួររកអ្នកសម្របសម្រួលធនធានគ្រួសារប្រចាំតំបន់របស់អ្នក ។

បេសកកម្មរបស់នាយកដ្ឋាននៃជនមានពិការភាពផ្នែកការលូតលាស់ (DDD) គឺដើម្បីប្រឹងប្រែងធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងជីវិតផងទាំងពួងរបស់បណ្តាជន ដែលមានលក្ខណសម្បត្តិសំរាប់សេវាកម្មនេះ តាមរយៈការផ្តល់ជូននូវកិច្ចឧបត្ថម្ភនិងសេវាបំរើប្រកបដោយគុណភាពល្អ ដែលមានលក្ខណៈ ៖ ជាបុគ្គល/គ្រួសារនិយម; មាំមួននិងបត់បែនតាមសភាពការណ៍; ពេញចិត្តចំពោះសាមីជននិងក្រុមគ្រួសាររបស់ពួកពេ; ហើយអាចជួបតាមសេចក្តីត្រូវការនិមួយៗ ។ កិច្ចឧបត្ថម្ភនិងសេវាកម្មនឹងត្រូវផ្តល់ជូនទៅតាមមធ្យោបាយ ដែលធានាឲ្យបណ្តាជនមានពត៌មានមូលដ្ឋាន ចាំបាច់ដើម្បីធ្វើការសម្រេចចិត្តអំពីជម្រើសរបស់ពួកពាត់ ហើយផ្តល់កាលៈទេសៈដ៏ប្រសើរបំផុតសំរាប់ជោគជ័យ ។

ភាពគ្មានការរើសអើង ៖ វាជាគោលនយោបាយរបស់ក្រសួងសង្គមកិច្ចនិសុខាភិបាល ដែលថា គ្មានជនណាម្នាក់នឹងត្រូវស្ថិតក្រោមការប្រកាន់រើសអើងនៅក្នុងទីភ្នាក់ងារនេះ ឬអ្នកជាប់កិច្ចសន្យារបស់គេ ដោយព្រោះពូជសាសន៍, ពណ៌សម្បុរ, ជាតិកំណើត, ភេទ, អាយុ, សាសនា, គោលជំនឿ, លក្ខណសម្បត្តិអាពាហ៍ពិពាហ៍, កង្វះសមត្ថភាព, អតីតយុទ្ធជនសម័យសង្គ្រាមវៀតណាម, ឬវត្តមានពិការភាពផ្នែករាងកាយ ផ្នែកសតិ ឬផ្នែកវិញ្ញាណទេ ។

# ទីកន្លែង

### តំបន់ 1 (N.E. Washington)

**1-800-462-0624**

Spokane
509-329-2900
TTY 509-568-3038

Colfax
509-397-5053

Colville
1-866-715-3646
509-685-5649

Moses Lake
509-764-5674

Omak
509-846-2098

Wenatchee
509-667-6164

### តំបន់ 2 (S.E. Washington)

**1-800-822-7840**

Yakima
509-225-4620
TTY 509-454-4321

Clarkston
509-751-4637

Ellensburg
509-925-0405

Kennewick
509-374-2111

Sunnyside
509-839-7114

Walla Walla
509-526-2580

Wapato
509-877-5190

Yakima Outstation
509-225-7970

### តំបន់ 3 (N.W. Washington)

**1-800-788-2053**

Everett
425-339-4833
TTY 425-339-4850

Bellingham
1-800-239-8285
360-714-5000
TTY 360-714-5002

Mt Vernon
1-800-491-5266
360-416-7261
TTY 360-416-7270

Oak Harbor
1-877-890-2631
360-240-4729

សំរាប់ពត៌មានបន្ថែម, ចូរអានមើលបណ្តាញអ៊ិនធឺណិត DDD នៅ ៖
http://www.dshs.wa.gov/ddd/index.shtml

### តំបន់ 4 (King County)

**1-800-314-3296**

Seattle
206-568-5700
TTY 206-720-3325

Kent
1-800-974-4428
253-372-5770
TTY 253-372-5759

### តំបន់ 5 (Pierce/Kitsap County)

**1-800-248-0949**

Tacoma
253-404-6500
TTY 253-572-7381

Bremerton
1-800-735-6740
360-475-3490
TTY (360-475-3492

### តំបន់ 6 (S.W. Washington និង Olympic Peninsula)

**1-800-339-8227**

Olympia
360-725-4250
TTY 360-586-4719

Aberdeen
360-537-4360

Centralia
360-807-7010

Kelso
360-501-2520
TTY 360-501-2489

Long Beach
360-642-6237

Port Angeles
1-877-601-2760
360-565-2700

Port Townsend
360-379-4324

Shelton
360-432-2039

South Bend
360-875-4244

Vancouver
1-888-877-3490
360-750-4250
TTY 360-690-4738

កម្មវិធីអន្តរាគមន៍បឋមវ័យសំរាប់ទារកនិងកុមារក្មេងខ្ចី (ក្រុង Olympia)
360-725-3500/TTY 360-407-1087

បណ្តាញទូរស័ព្ទសុខភាពគ្រួសារ
1-800-322-2588

ការិយាល័យកណ្តាលនៃនាយកដ្ឋាន DDD (ក្រុង Olympia)
360-725-3413